# វ៉ាក់សាំង COVID-19

## អ្នកត្រូវដឹងក្បោះក្បាយ អំពីវ៉ាក់សាំង COVID-19*

### វាគឺមានសុវត្ថិភាព

**ការមានវ៉ាក់សាំង COVID-19 គឺត្រូវបានអនុញ្ញាតដោយ FDA និងបានឲ្យអនុសាសន៍ដោយ គណៈកម្មាធិការទីប្រឹក្សាស្តីពីការអនុវត្តន៍ចាក់ថ្នាំការពាររោគ (Advisory Committee on Immunization Practices) របស់ CDC។**

វ៉ាក់សាំងបានប្រព្រឹត្តតាមជំហានដូចៗគ្នា សំរាប់ការពិសោធន៍ និងការទទួលស្គាល់ ដែលបានប្រើសំរាប់វ៉ាក់សាំងទាំងអស់។ វាបានផលិតឡើងយ៉ាងរហ័ស ប៉ុន្តែមិនដែលបានធ្វេសប្រហែសលើសុវត្ថិភាពទេ។ សំរាប់សេចក្តីពិស្តារថែមទៀត ស្តីពីសុវត្ថិភាពវ៉ាក់សាំង ទស្សនា **mass.gov/COVIDVaccineSafety**

### វាគឺឥតគិតថ្លៃ

**វ៉ាក់សាំង COVID-19 គឺកំពុងតែបានចាក់ឲ្យ ដោយឥតគិតថ្លៃ ទៅដល់បុគ្គលទាំងអស់ ដោយរដ្ឋាភិបាលសហព័ន្ធ។**

អ្នកអាចនឹងបានស្នើសុំ ព័ត៌មានធានារ៉ាប់រងរបស់អ្នក ប្រយោជន៍ឲ្យអ្នកចាក់ថ្នាំឲ្យអ្នក អាចចេញវិក្កយប័ត្រ ទៅក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក។ តែយ៉ាងណាមិញ អ្នកនឹងមិនត្រូវបានទារថ្លៃឡើយ។ បើសិនអ្នកពុំមានការធានារ៉ាប់រងទេ អ្នកនៅតែមានសិទ្ធិទទួលវ៉ាក់សាំង ដោយឥតទារថ្លៃ។

### អ្នកអាចនឹងត្រូវការវ៉ាក់សាំងពីរដូស្ស ដើម្បីបានចាក់វ៉ាក់សាំងពេញលេញ

**ទំរាំនឹងអ្នកបានចាក់វ៉ាក់សាំងពេញលេញ អ្នកនៅតែអាចកើត និងចំឡងជំងឺ COVID-19 ទៀតដែរ។**

- **វ៉ាក់សាំង Pfizer៖** យ៉ាងហោច **21 ថ្ងៃ** ក្រោយពីដូស្សទីមួយ
- **វ៉ាក់សាំង Moderna៖** យ៉ាងហោច **28 ថ្ងៃ** ក្រោយពីដូស្សទីមួយ
- **វ៉ាក់សាំង Johnson & Johnson (Janssen)៖** តែ**មួយ** ដូស្សប៉ុណ្ណោះ

មិនមែនគ្រប់ៗគ្នានឹងបានចាក់វ៉ាក់សាំង នៅពេលអ្នកចាក់ឡើយ។ ហើយក្នុងខណៈយើងដឹង ថាវ៉ាក់សាំងកាត់បន្ថយករណីនិងរោគសញ្ញាធ្ងន់ធ្ងរ បានច្រើន យើងក៏កំពុងតែសិក្សាទៀត អំពីការការពារដែលវាផ្តល់។ ចូរបន្តពាក់ម៉ាស្ក, លាងដៃរបស់អ្នក, រក្សាគម្លាត, និងជៀសវាងក្រុមមនុស្ស សូម្បីតែបន្ទាប់ពីអ្នកបានចាក់វ៉ាក់សាំងពេញលេញក៏ដោយ។

### ដូស្សទីពីររបស់អ្នក គួរតែបានចាក់នៅទីតាំងដូចគ្នា

**អ្នកត្រូវតែទទួលដូស្សទីពីររបស់អ្នក នូវវ៉ាក់សាំងដូចគ្នា នៅទីតាំងដូចនឹងលើកដំបូងរបស់អ្នកដែរ។**

ដូច្នេះហើយ មុននឹងចាកចេញពីការណាត់ជួប នៃការចាក់ដូស្សទីមួយរបស់អ្នក ត្រូវគ្រោងពេល ឬបញ្ជាក់របៀបដើម្បីរៀបចំការណាត់ជួបរបស់អ្នក លើកក្រោយទៀត (សំរាប់ Pfizer និង Moderna)។

* ព័ត៌មាននេះបានទាន់បច្ចុប្បន្នភាព ចុងក្រោយនៅ 4/19/2021 និងអនុវត្តចំពោះវ៉ាក់សាំង Moderna និង Pfizer និង Johnson & Johnson (Janssen)។

**សំរាប់ព័ត៌មានថែមទៀត ទស្សនា Mass.gov/COVIDvaccine**